**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១៥២៧...អ.ន.ក

ថ្ងៃច័ន្ទ ៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី...០២...ខែ...កញ្ញា...ឆ្នាំ២០១៩

## សូមគោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**កម្មវត្ថុ** : របាយការណ៍ប្រចាំខែសីហាស្តីពី ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ " គិតត្រឹមថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ "។

**ជូនភ្ជាប់** : របាយការណ៍លម្អិតប្រចាំខែសីហាស្តីពី ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ " គិតត្រឹមថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ " ចំនួន ........................................ ០១ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ " គិតត្រឹមថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ "សម្រេចបាន:

ក. ដំណាំស្រូវ : ស្ទូង និងព្រោះអនុវត្តបានចំនួន ២ ៤៨០ ៥៥៩ ហ.ត ស្មើនឹង ៩៥,៩២ %
នៃផែនការចំនួន ២ ៥៨៦ ១៥២ ហ.ត យឺតជាងឆ្នាំមុន ៩៤ ៥២៣ ហ.ត

ខ. ដំណាំរួមផ្សំ : អនុវត្តបាន ៤៦ ៦៨៨ ហ.ត លឿនជាងឆ្នាំមុន ១ ៥៥១ ហ.ត

គ. ដំណាំឧស្សាហកម្ម : អនុវត្តបាន ៧៦៥ ១៥៥ ហ.ត យឺតជាងឆ្នាំមុន ៧៣ ៥៥៨ ហ.ត

បច្ចុប្បន្នកសិករ បាននិងកំពុងប្រមូលផលស្រូវដើមរដូវវស្សាលើផ្ទៃដីចំនួន ៧៦០ ១៣៦ ហ.ត ស្មើនឹង ៦,៧៦% នៃផ្ទៃដីអនុវត្ត ដោយទទួលបានទិន្នផលជាមធ្យម ៤,២១២ ត/ហ.ត និងបរិមាណផល ៧០៦ ៦៥៧ ត។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ងិន ឆាយ**

**ចម្លងជូន ៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានកសិកម្ម
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427